**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦១)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ យឹម ទិត្យ

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 27-Mar-2020, 09:42
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤**

---

**ដាក់ដោយ៖**

**សហមេធាវី**

សូ មូស្សេទ្ធី
Suzana TOMANOVIĆ

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ៖**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម BAIK Kang Jin

ចៅក្រម ហួត វុទ្ធី

ចៅក្រមបម្រុង ប៉ែន ពេជ្រសាលី

ចៅក្រមបម្រុង Steven J. BWANA

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤**

## សេចក្តីផ្តើម

១.	លោក **យឹម ទិត្យ** តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន (“មេធាវីការពារក្តី”) សូមដាក់ការឆ្លើយតបរបស់ យឹម ទិត្យ ទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង០០៤ (“ការឆ្លើយតប” និង “ចម្លើយតប”)។ ចម្លើយតបគួរត្រូវបានបដិសេធចោល ដោយសារតែចម្លើយតបមិនបានផ្តល់ភស្តុតាងគាំទ្រ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា មេធាវីការពារក្តីបានបង្ហាញដោយមិនត្រឹមត្រូវអំពីផលវិបាកនៃដីកាដែលខុសច្បាប់ ហើយថា សំណើដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍គឺផ្ទុយនឹងច្បាប់។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិផ្អែកលើមូលដ្ឋានមិនត្រឹមត្រូវថា លោក យឹម ទិត្យ ត្រូវបានចោទប្រកាន់បញ្ជូនទៅជំនុំជម្រះដោយស្របច្បាប់។ សហព្រះរាជអាជ្ញាអន្តរជាតិបកស្រាយតាមការរៀបចំរបស់ខ្លួនទៅលើការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ (អ.ប.ជ) នៅក្នុងសំណុំរឿង០០៤/០២ ដែលថា មិនមានមូលដ្ឋានគតិយុត្តិសម្រាប់សហចៅក្រមស៊ើបអង្កេត ចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា ដោយបកស្រាយការសម្រេចនេះថាមិនអាចអនុវត្តបានចំពោះដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (“ស.ច.ស.អ” និង“ដីកាដំណោះស្រាយរបស់ ស.ច.ស.អ”) ប៉ុន្តែអាចអនុវត្តបានចំពោះដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ[1]។ សហព្រះរាជអាជ្ញាអន្តរជាតិក៏មិនបានយកចិត្តទុកដាក់ចំពោះផលវិបាកជាក់ស្តែងនៃការសម្រេចដែលថា ដីកាដំណោះស្រាយដែលចេញដោយខុសច្បាប់ ត្រូវបានចាត់ទុកថា មោឃៈ និងគ្មានសុពលភាព។ អង្គបុរេជំនុំជម្រះគួរច្រានចោលដីកាដំណោះស្រាយដែលមានវិការៈនេះ និងអាចធ្វើដោយ (i) លើកលែងការចោទប្រកាន់ទាំងស្រុង និងលើកលែងការចោទប្រកាន់ប្រឆាំងនឹងលោក យឹម ទិត្យ (ii) បង្វិលសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេតវិញ ដើម្បីចេញដីកាដំណោះស្រាយរួមគ្នាមួយ ឬក៏ (iii) វាយតម្លៃសំណុំរឿង ០០៤ រួចហើយចេញដីកាដំណោះស្រាយខ្លួនឯងផ្ទាល់។

## ប្រវត្តិនីតិវិធី

២.	មេធាវីការពារក្តីបញ្ចូលប្រវត្តិនីតិវិធីដែលមានក្នុង*ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងសេចក្តី*

[1] ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D381។ ដីកាដំណោះស្រាយចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩ ឯកសារ D382។

*សន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ* [2] នៅក្នុង *បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤*[3] និងនៅក្នុង *បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងសំណុំរឿង ០០៤*[4]។

៣. នៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់*បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ* ("បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ")[5]។

៤. នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩ សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានដាក់*បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិក្នុងសំណុំរឿង ០០៤*[6]។

៥. នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ មេធាវីការពារក្តីបានដាក់*សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និង ពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ*[7]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានឆ្លើយតបនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩[8]។

---

[2] ចម្លើយតបរួមរបស់ យឹម ទិត្យ ទៅនឹងដីការសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ D378/5 កថាខណ្ឌ ១៤-១០៥។

[3] បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/18 ("បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួន ២") កថាខណ្ឌ ៤-១០។

[4] បណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D382/22 កថាខណ្ឌ ៣-៩។

[5] បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ យឹម ទិត្យ (D381) ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/19។

[6] បណ្តឹងឧទ្ធរណ៍របស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/20។

[7] សំណើបន្ទាន់របស់ យឹម ទិត្យ សុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបរបស់គាត់ទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/21 និង D382/23។

៦. នៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ អង្គបុរេជំនុំជម្រះបានចេញ*សេចក្ដីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រនិងពេលវេលាកំណត់សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង០០៤*[9]។

៧. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤*[10]។

៨. នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង ០០៤* ដោយគណនាកាលបរិច្ឆេទកំណត់ខុស ផ្អែកលើពេលវេលាកំណត់ដប់ថ្ងៃ តាមសេចក្ដីណែនាំអនុវត្ត ស្ដីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក[11] ដោយមិនគណនាតាមពេលវេលាកំណត់ដែលអង្គបុរេជំនុំជម្រះបានដាក់ចេញ[12]។

[8] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់របស់ យឹម ទិត្យ ទាក់ទងនឹងបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ ឯកសារ D381/23 និង D382/25។

[9] សេចក្ដីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ D381/24 និង D382/26។

[10] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/27។

[11] ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរនៅក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/25 និង D382/28 កថាខណ្ឌ ៧ ("ចម្លើយតបរបស់ ស.ព.អ."), សូមមើលផងដែរ សេចក្ដីណែនាំអនុវត្តស្ដីអំពីការដាក់ឯកសារនៅ អ.វ.ត.ក. លេខ ECCC/01/2007/Rev.8 វិសោធនកម្មនៅថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ មាត្រា ៨(៣)។

[12] សេចក្ដីសម្រេចលើសំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ចម្លើយតបពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០២០ ឯកសារ D381/24 និង D382/26 ទំព័រ ៤។ អ.ប.ជ. "អនុញ្ញាតឱ្យភាគីដាក់ចម្លើយតបចំនួន ៦០ ទំព័រ ក្នុងរយៈពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃជូនដំណឹងពីការបកប្រែបណ្ដឹងឧទ្ធរណ៍នីមួយៗ"។

**ការឆ្លើយតប ÷ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញថា មេធាវីការពារក្តីបង្ហាញមិនត្រឹមត្រូវពីផលវិបាកនៃដីកាដំណោះស្រាយខុសច្បាប់ និងថា សំណើដែលមេធាវីការពារក្តីស្នើឡើងផ្ទុយនឹងច្បាប់**

៩. សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងដោយមិនត្រឹមត្រូវថា មេធាវីការពារក្តីបង្ហាញមិនបានត្រឹមត្រូវពីផលវិបាកនៃការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ "ពាក់ព័ន្ធនឹងផលប៉ះពាល់នៃកំហុសឆ្គងនេះលើស្ថានភាពផ្លូវច្បាប់នៃដីកាដំណោះស្រាយនីមួយៗ"[13]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងដោយមិនត្រឹមត្រូវបន្ថែមទៀតថា "បណ្តឹងឧទ្ធរណ៍ប្រឆាំងដីកាដំណោះស្រាយពីរ គួរតែត្រូវបានបដិសេធចោល ដោយហេតុថា ដំណោះស្រាយដែលបានស្នើសុំផ្ទុយទៅនឹងពាក្យពេចន៍នៃកិច្ចព្រមព្រៀង អ.វ.ត.ក ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុង ក៏ដូចជាយុត្តិសាស្ត្រដ៏ស៊ីសង្វាក់គ្នារបស់ អ.វ.ត.ក ផងដែរ"[14]។ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញភស្តុតាងគាំទ្រការអះអាងទាំងអស់នេះទេ។ ទោះបីជាសហព្រះរាជអាជ្ញាអន្តរជាតិបានបញ្ជាក់ថាគាត់ "មិនជំទាស់" ចំពោះការសម្រេច "ជាឯកច្ឆ័ន្ទ" របស់អង្គបុរេជំនុំជម្រះ ដែលថា "ការចេញដីកាដំណោះស្រាយពីរខ្វែងគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺ "ខុសច្បាប់ ហើយរំលោភទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក"[15] ក្តី តែចម្លើយតបរបស់គាត់គឺផ្អែកលើមូលដ្ឋានខុសថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយស្របច្បាប់ មានអត្ថិភាពនៅក្នុងសំណុំរឿង ០០៤ ហើយដែលអង្គជំនុំជម្រះសាលាដំបូងអាចជំនុំជម្រះលោក យឹម ទិត្យ។ ការមិនយកចិត្តទុកដាក់ទៅលើស្ថានភាពនីតិវិធីបច្ចុប្បន្នក្នុងសំណុំរឿង ០០៤ និងការបញ្ជាក់អំពីគោលជំហរប្តឹងឧទ្ធរណ៍ដែលបានចាប់ផ្តើមមុនពេលអង្គបុរេជំនុំជម្រះចេញសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង ០០៤/០២ នោះ តាមការរៀបចំរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិបានបន្ទរិភាគដោយខុសលើការសម្រេចរបស់អង្គបុរេជំនុំជម្រះ ដោយមិនបានទទួលស្គាល់ពីផលវិបាកផ្ទាល់ចំពោះ សំណុំរឿង ០០៤ ដែលថាស្ថានភាពគតិយុត្តិរបស់ដីកាដំណោះស្រាយនីមួយៗ គឺជាមោឃៈ និងគ្មានសុពលភាពរួចទៅហើយ។

---

[13] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៧។

[14] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៣។

[15] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៦, ២៧ (ដាក់អក្សរទ្រេតក្នុងច្បាប់ដើម)។

## I. សហព្រះរាជអាជ្ញាអន្តរជាតិវិភាគខុស និងតាមការរៀបចំរបស់ខ្លួន លើការសម្រេចជាឯកច្ឆ័ន្ទ របស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤/០២

១០. សហព្រះរាជអាជ្ញាអន្តរជាតិបានដកស្រង់ការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង០០៤/០២ ដែលថា ដីកាដំណោះស្រាយពីរដាច់ពីគ្នា មិនមានមូលដ្ឋានគតិយុត្តិឡើយ ប៉ុន្តែផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិបែរជាលើកទឡ្ហីករណ៍ថា លោក យឹម ទិត្យ គួរត្រូវបានជំនុំជម្រះដោយផ្អែកលើដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដែលខុសច្បាប់និងមានវិការៈនីតិវិធី) នៅក្នុងសំណុំរឿង ០០៤[16]។ ដើម្បីអនុវត្តដូច្នេះបាន សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា "បានដឹងអំពីសេចក្តីប្រកាសជាឯកច្ឆ័ន្ទនាពេលថ្មីៗនេះរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង០០៤/២"[17] ប៉ុន្តែ តាមពិតទៅគាត់បែរជាព្យាយាមធ្វើឲ្យមានការយល់ច្រលំលើសេចក្តីសម្រេចជាឯកច្ឆ័ន្ទ និងបកស្រាយដោយប្រើភាពមិនច្បាស់លាស់លើសំអាងហេតុរបស់អង្គបុរេជំនុំជម្រះ ដែលតាមជាក់ស្តែងមិនមានបែបនេះឡើយ។

១១. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា គាត់គោរពតាមការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ ដោយបញ្ជាក់ថា គាត់ "មិនជំទាស់ទៅនឹងទិដ្ឋភាពនៃបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយចំនួនពីរនេះទេ"[18] ហើយមានចេតនាលះបង់គោលជំហរដែលគាត់បានប្រកាន់ក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់គាត់ដែលបានធ្វើឡើងមុនសេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២។ ការត្រួតពិនិត្យឲ្យបានជិតដិតទៅបង្ហាញថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានទទួលយកការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះដែលថា ដីកាដំណោះស្រាយទាំងពីរមិនមានមូលដ្ឋានលើគតិយុត្តិឡើយ។ ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមគេចចេញព្រមទាំងជំទាស់ចំពោះការសម្រេចជាឯកច្ឆ័ន្ទ ហើយអាចត្រូវបានបកស្រាយថា សំណើសុំឲ្យធ្វើការពិចារណាឡើងវិញ ទៅលើការសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលមិនបានបំពេញតាមបទដ្ឋានដែលបានតម្រូវ[19] ឬជាការព្យាយាមដែលគ្មានការអនុញ្ញាត ក្នុងការដាក់បណ្តឹងឧទ្ធរណ៍

---

[16] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៩-៣៨, ៤៣។

[17] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៦។

[18] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៧។

[19] សំណុំរឿង០០២សាលដីកាសម្រេចអំពីការពិចារណាជាថ្មីឡើងវិញអំពីការទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១១ ឯកសារ D250/3/2/1/8 កថាខណ្ឌ ៦ ("នៅក្នុងយុត្តិសាស្ត្រកាលពីមុន អ.ប.ជ. បានអនុវត្ត

ប្រឆាំងនឹងការសម្រេចរបស់អង្គបុរេជំនុំជម្រះ ដែលត្រូវបានហាមឃាត់ដោយវិធាន ៧៧(១៣) នៃវិធានផ្ទៃក្នុង[20]។

១២. សហព្រះរាជអាជ្ញាអន្តរជាតិបានបកស្រាយដោយខុស និងតាមការរៀបចំរបស់ខ្លួន ចំពោះការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ ដែលមិនអនុវត្តចំពោះដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងទឡ្ហីករណ៍បែបសន្មត ដែលថា មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលស្របច្បាប់មួយ ដែលអាចជំនុំជម្រះលោក យឹម ទិត្យ។ ទឡ្ហីករណ៍នេះជាការសន្មតដោយសារតែសហព្រះរាជអាជ្ញាអន្តរជាតិចង់បញ្ជូនលោក យឹម ទិត្យ ទៅជំនុំជម្រះ ទោះជាក្នុងតម្លៃណាក៏ដោយ ហើយសហព្រះរាជអាជ្ញាអន្តរជាតិលើកសំអាងហេតុក្លែងក្លាយ ដោយផ្អែកលើគោលដៅនេះ មិនមែនផ្អែកលើមូលដ្ឋានគតិយុត្តិឡើយ។ សហព្រះរាជអាជ្ញាអន្តរជាតិអះអាងថា "ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិស្របគ្នាជាមួយនឹងច្បាប់នីតិវិធីជាធរមាន ដូច្នេះត្រូវតែតម្កល់"[21] ហើយលើកឡើងថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ដីកាសម្រេចលើកលែងចោទប្រកាន់ ដែលចេញអនុលោមទៅតាមវិធាន ៦៧(៣) នៃវិធានផ្ទៃក្នុង "គឺមិនត្រូវបានចេញដោយត្រឹមត្រូវទេ ដូច្នេះគួរត្រូវបានច្រានចោលដោយឈរលើមូលដ្ឋាននេះតែមួយ"[22]។ នេះគឺជាការបកស្រាយដោយគ្មានសំអាងហេតុ និងតាមការរៀបចំរបស់ខ្លួន ទៅលើការសម្រេចរបស់ អង្គបុរេជំនុំជម្រះដែលថា សហចៅក្រមស៊ើប

---

លក្ខណវិនិច្ឆ័យដូចតទៅសម្រាប់ការពិចារណាសារជាថ្មីឡើងវិញ"[...]សំណើសុំពិចារណាសារជាថ្មីឡើងវិញអាចជោគជ័យបានតែក្នុងករណីមានមូលដ្ឋានធម្មានុរូបសម្រាប់អង្គជំនុំបុរេជម្រះធ្វើការពិចារណាសារជាថ្មីឡើងវិញអំពីសេចក្តីសម្រេចនានាកាលពីមុនរបស់ខ្លួនប៉ុណ្ណោះ។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានលើកឡើងថា អង្គជំនុំជម្រះ "តែងតែអាចធ្វើការពិចារណាសាជាថ្មីឡើងវិញអំពីសេចក្តីសម្រេចដែលខ្លួនបានធ្វើកាលពីមុន មិនត្រឹមតែដោយសារកាលៈទេសៈប្រែប្រួលប៉ុណ្ណោះទេ តែថែមទាំងនៅពេលដែលអង្គជំនុំជម្រះបានដឹងថា សេចក្តីសម្រេចកាលពីមុនធ្វើឡើងដោយភ័ន្តច្រឡំ ឬថា សេចក្តីសម្រេចនោះបានបណ្តាលឱ្យមានភាពអយុត្តិធម៌"។ [...] បទដ្ឋានសម្រាប់ការពិចារណាជាថ្មីឡើងវិញក៏ត្រូវបានពណ៌នាផងដែរដូចតទៅនេះ "អង្គជំនុំជម្រះមានអំណាចឆន្ទានុសិទ្ធិជាប់ជាមួយជាមូលដ្ឋាន ដើម្បីធ្វើការពិចារណាសាជាថ្មីឡើងវិញ អំពីសេចក្តីសម្រេចបន្ទាន់បន្ទំកាលពីមុននៅក្នុងករណីលើកលែង "ប្រសិនមានការបង្ហាញថាមានការភ័ន្តច្រឡំច្បាស់លាស់ក្នុងសំអាងហេតុ ឬប្រសិនបើចាំបាច់ធ្វើដូច្នេះ ដើម្បីការពារមិនឱ្យមានភាពអយុត្តិធម៌" (គូសបន្ទាត់ពីក្រោមក្នុងច្បាប់ដើម) (លុបចោលការដកស្រង់ខាងក្នុង)។

[20] វិធាន ៧៧(១៣) ចែងនៅក្នុងផ្នែកពាក់ព័ន្ធថា "សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសម្លេងគាំទ្រជាវិជ្ជមានពីចៅក្រម ៤(បួន) រូបយ៉ាងតិច។ សេចក្តីសម្រេចនេះត្រូវបិទផ្លូវតវ៉ា"។

[21] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៣០-៣៨។

[22] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៣៨។

អង្កេតទាំងពីរ "បានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏ធំធេង" និង "រំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក" ដោយចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា[23]។

១៣. ទោះបីជាមើលទៅហាក់ដូចជាគោរពចំពោះការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ ដោយលើកឡើងថា ការសម្រេចនេះ "ជាឯកច្ឆ័ន្ទ"[24] ក្តី ប៉ុន្តែ សហព្រះរាជអាជ្ញាអន្តរជាតិចោទជាសំណួរចំពោះការសម្រេចនេះដោយលើកឡើងថាអង្គបុរេជំនុំជម្រះបាន "បញ្ជាក់ជាដដែលៗ និងជាឯកច្ឆ័ន្ទថាសហចៅក្រមស៊ើបអង្កេតមិនត្រូវបានតម្រូវឱ្យចេញដីកាសម្រេចរួមនោះទេ"[25]។ ការលើកឡើងនេះបង្ហាញដោយមិនត្រឹមត្រូវអំពីការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ។ សហព្រះរាជអាជ្ញាអន្តរជាតិ ផ្តុះបញ្ចាំងដោយមិនត្រឹមត្រូវអំពីផ្នែកមួយនៃនីតិវិធីរបស់ អ.វ.ត.ក ដែលអង្គបុរេជំនុំជម្រះបានពិចារណា ហើយបានលើកឡើងដោយមិនត្រឹមត្រូវថា អង្គបុរេជំនុំជម្រះមានជំហរថាសហចៅក្រមស៊ើបអង្កេតមិនត្រូវបានតម្រូវឱ្យចេញដីកាដំណោះស្រាយរួមគ្នាឡើយ។ អង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងច្បាស់លាស់ ផ្ទុយពីនេះ គឺថា សហចៅក្រមស៊ើបអង្កេតអាចចេញដីកាដំណោះស្រាយ *តែមួយ* ប៉ុណ្ណោះ[26]។

១៤. សហព្រះរាជអាជ្ញាអន្តរជាតិពឹងផ្អែកទៅលើកត្តាគោលនយោបាយដែលមិនមានភាពពាក់ព័ន្ធ ដើម្បីគាំទ្រទឡ្ហីករណ៍គតិយុត្តិដែលខុសឆ្គងរបស់គាត់ ដែលថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាំបាច់ត្រូវបន្តទៅជំនុំជម្រះ[27]។ សហព្រះរាជអាជ្ញាអន្តរជាតិបានទទួលស្គាល់ថា អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេត "បានប្រព្រឹត្តកំហុសផ្នែកច្បាប់ និងខកខានមិនបានប្រើប្រាស់ឱ្យបានល្អិតល្អន់នូវនីតិវិធីចាំបាច់ ដើម្បីដោះស្រាយការខ្វែងយោបល់គ្នារបស់ខ្លួន"[28]។ នៅក្នុងពេលជាមួយគ្នានេះ សហព្រះរាជអាជ្ញាអន្តរជាតិបានបន្តអះអាងដោយខុសឆ្គងថា ដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា អាចធ្វើទៅបាន ដោយបន្តអះអាង ដូចដែលគាត់បានអនុវត្តនៅក្នុងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើប

---

[23] សំណុំរឿង ០០៤/០២ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១៩ ឯកសារ D359/24 និង D360/33 ("សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២") កថាខណ្ឌ ៨៩, ៩៨, ៩៩ និងទំព័រ ៦១។

[24] ចម្លើយតបរបស់ ស.ព.អ. កថាខណ្ឌ ២៧។

[25] ចម្លើយតបរបស់ ស.ព.អ. កថាខណ្ឌ ២៩។

[26] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ១២១។

[27] ចម្លើយតបរបស់ ស.ព.អ. កថាខណ្ឌ ២៦, ២៨-៣៨។

[28] ចម្លើយតបរបស់ ស.ព.អ. កថាខណ្ឌ ២៥-២៦។

អង្កេតជាតិ ដែលថា គុណវិបត្តិនៃការតម្រូវឱ្យមានដីកាដំណោះស្រាយតែមួយ រួមមាន ការរំលោភបំពានទៅលើឯករាជ្យភាពតុលាការ និងការធ្វើឱ្យប៉ះពាល់ដល់តម្លាភាព[29]។ ការសម្រេចរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤/០២ ធ្វើឱ្យកត្តាគោលនយោបាយទាំងអស់នេះ លែងមានភាពពាក់ព័ន្ធចំពោះកិច្ចដំណើរការនីតិវិធីបច្ចុប្បន្ន[30]។

១៥. ជាការមិនអាចជំទាស់បានដែលថា ចៅក្រមអង្គបុរេជំនុំជម្រះបានចុះហត្ថលេខាលើផ្នែកសម្រេចសេចក្តីជាឯកច្ឆ័ន្ទលើសំណុំរឿង ០០៤/០២ ដែល "ប្រកាសថា ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នារបស់សហចៅក្រមស៊ើបអង្កេត គឺខុសច្បាប់ ហើយរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក"[31]។ អង្គបុរេជំនុំជម្រះសម្រេចថា ជាការច្បាស់លាស់ និងមិនស្រពិចស្រពិលឡើយដែលថា តាមក្របខណ្ឌច្បាប់ អ.វ.ត.ក ដីកាដំណោះស្រាយចាំបាច់ត្រូវតែជា សេចក្តីសម្រេចតែមួយ ហើយក្របខណ្ឌ *មិនអនុញ្ញាតឱ្យមាន* ការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នាឡើយ[32]។ អង្គបុរេជំនុំជម្រះបានសម្រេចថា សហចៅក្រមស៊ើបអង្កេត "បានប្រព្រឹត្តកំហុសអង្គច្បាប់ដ៏ធំធេង"[33] "ចេញដីកាដំណោះស្រាយពីរផ្សេងគ្នា ផ្ទុយគ្នាក្នុងពេលតែមួយ ដែលមិនធ្លាប់មានពីមុនមក នៅក្នុងសំណុំរឿងតែមួយ"[34] ហើយថា សហចៅក្រមស៊ើបអង្កេតបាន "រំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ប្រាសចាកពីតួនាទីខ្ពស់បំផុតរបស់ពួកគេ និងបង្កើតជាស្ថានភាពគតិយុត្តិដែលមិនធ្លាប់មាន ដែលធ្វើឱ្យប៉ះពាល់ដល់មូលដ្ឋានសំខាន់ៗនៃអង្គភាពតុលាការរបស់ពួកគេ"[35]។ អង្គបុរេជំនុំជម្រះក៏បានសម្រេចថា "កំហុសដែលសហចៅក្រមស៊ើបអង្កេតបានប្រព្រឹត្តនៅក្នុងសំណុំរឿងនេះ ធ្វើឱ្យខូចខាតដល់មូលដ្ឋាននៃប្រព័ន្ធចម្រុះ និងមុខងារដ៏ត្រឹមត្រូវរបស់ អ.វ.ត.ក"[36]។ ការសម្រេចលើអង្គច្បាប់ដោយឯកច្ឆ័ន្ទនៅក្នុងសំណុំរឿង០០៤/០២ ចាំបាច់

[29] ចម្លើយតបរបស់ ស.ព.អ. កថាខណ្ឌ ២៥។

[30] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ១២១ ទំព័រ ៨៩។

[31] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ ទំព័រ ៨៩។

[32] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ១២០។

[33] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២, កថាខណ្ឌ ៩៨, ៩៩។

[34] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ៩៨។

[35] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ៩៩។

[36] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ១២៣។

ត្រូវអនុវត្តចំពោះសំណុំរឿង ០០៤[37]។

១៦. សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិពឹងផ្អែកលើអាកប្បកិរិយាចោទប្រកាន់ ដែលមិនចេះហត់នឿយ និងជាប្រចាំ ចំពោះសំណុំរឿង០០៤ ដែលត្រូវបន្តលើកទឡ្ហីករណ៍ជំរុញឱ្យមានការជំនុំជម្រះ លោក យឹម ទិត្យ ទោះបីជាមិនមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលចេញដោយស្របច្បាប់ក្តី។ សហព្រះរាជអាជ្ញាអន្តរជាតិហាក់ដូចជាមានចេតនារក្សាអាកប្បកិរិយា "គោលដៅចុងក្រោយផ្តល់យុត្តិកម្មដល់មធ្យោបាយផ្សេងៗ" នៅក្នុងគ្រប់ស្ថានភាពនីតិវិធីទាំងអស់ ដោយមិនគិតអំពីឧបសគ្គផ្លូវច្បាប់ណាមួយឡើយ សូម្បីតែនៅពេលដែលដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវបានកំណត់ថាមិនមានមូលដ្ឋានច្បាប់ក្តី។ ចំណុចនេះបង្ហាញច្បាស់តាមរយៈការព្យាយាមកន្លងមករបស់សហព្រះរាជអាជ្ញាអន្តរជាតិក្នុងការវិភាគដោយមិនត្រឹមត្រូវ និងតាមការរៀបចំរបស់ខ្លួន លើការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ ដើម្បីលើកទឡ្ហីករណ៍ថា មានតែដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិតែមួយ ដែលមានសុពលភាព។

---

[37] អង្គបុរេជំនុំជម្រះយល់ឃើញថា អង្គបុរេជំនុំជម្រះ "ត្រូវធានាថា "ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ជនត្រូវចោទ ជនជាប់ចោទ និងជនរងគ្រោះ ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព" គ្រប់ពេលក្នុងដំណាក់កាលនៅមុនពេលជំនុំជម្រះ" សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ៥១ ដកស្រង់វិធាន ២១ នៃវិធានផ្ទៃក្នុង។ "ចំណុចជាសារវ័ន្តមួយនៃវិធានច្បាប់ គឺ គោលការណ៍សច្ចភាពគតិយុត្តិ ដែលតម្រូវផងដែរថា នៅពេលដែលតុលាការសម្រេចជាស្ថាពរទៅលើបញ្ហាមួយ ការសម្រេចនេះមិនគួរបណ្តាលឱ្យមានបញ្ហាចោទឡើងឡើយ" តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស *Brumărescu* *តទល់នឹងប្រទេសរ៉ូម៉ានី* សំណើសុំលេខ ២៨៣៤២/៩៥ សាលក្រម ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦១, តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស រឿងក្តី *Kehaya* *និងអ្នកផ្សេងទៀត តទល់នឹងប្រទេសប៊ុលហ្គារី* សំណើសុំលេខ ៤៧៧៩៧/៩៩ និងលេខ ៦៨៦៩៨/០១ សាលក្រម ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៦ កថាខណ្ឌ ៦១, តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស រឿងក្តី *Ryabykh* *តល់ទល់នឹងប្រទេសរុស្ស៊ី* សំណើសុំលេខ ៥២៨៥៤/៩៩ សាលក្រម ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៣ កថាខណ្ឌ ៥១។ "ក្នុងករណីមានការដាច់ចេញពីគ្នាក្នុងការអនុវត្តបទប្បញ្ញត្តិច្បាប់ ដែលមានភាពប្រហាក់ប្រហែលគ្នាខ្លាំងចំពោះបុគ្គលនៅក្នុងក្រុមដែលសឹងតែដូចគ្នាបេះបិទ បញ្ហានៃសច្ចភាពគតិយុត្តិនឹងកើតមានឡើង"។ តុលាការអឺរ៉ុបសម្រាប់សិទ្ធិមនុស្ស រឿងក្តី *Ştefănică* *និងអ្នកផ្សេងទៀត តទល់នឹងប្រទេសរ៉ូម៉ានី* បណ្តឹងលេខ ៣៨១៥៥/០២ សាលក្រម ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០១០ កថាខណ្ឌ ៣៧ (លុបចោលការដកស្រង់ខាងក្នុង)។ ការជំនុំជម្រះសម្រេចដែលមិនស៊ីសង្វាក់គ្នាអំពីបណ្តឹងដែលប្តឹងដោយបុគ្គលដែលស្ថិតក្នុងស្ថានភាពប្រហែលគ្នា នឹងនាំទៅដល់ស្ថានភាពមិនប្រាកដប្រជាដែលធ្វើឱ្យទំនុកចិត្តរបស់សាធារណជនចំពោះតុលាការបានថយចុះ ហើយនឹងដកហូតសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ពីបុគ្គល។ សូមមើលដូចយោងខាងលើ កថាខណ្ឌ ៣៨។

## II. សហព្រះរាជអាជ្ញាអន្តរជាតិមិនយកចិត្តទុកដាក់ដល់ផលវិបាកច្បាស់ក្រឡែតនៃការសម្រេចរបស់អង្គបុរេជំនុំជម្រះដែលថា ដីកាដំណោះស្រាយទាំងពីរគឺមោឃៈ

១៧. ការមិនទទួលស្គាល់ថា ផលវិបាកច្បាស់លាស់នៃការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង០០៤/០២ គឺថា ស្ថានភាពគតិយុត្តិរបស់ដីកាដំណោះស្រាយនីមួយៗ នៅក្នុងសំណុំរឿង០០៤ គឺមោឃៈ[38] នោះ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញថា បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ បានបង្ហាញដោយមិនត្រឹមត្រូវពីផលវិបាកនៃដីកាដំណោះស្រាយដែលខុសច្បាប់ និងថា សំណើដែលបានស្នើឡើងផ្ទុយនឹងច្បាប់។

១៨. ជារឿងច្របូកច្របល់ដែលសហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមបង្កើតនូវភាពខុសគ្នាដោយមិនត្រឹមត្រូវរវាងការចេញដីកាដំណោះស្រាយដោយស្របច្បាប់ និងភាពស្របច្បាប់នៃដីកាដំណោះស្រាយផ្ទាល់[39]។ មិនមានការញែកចេញពីគ្នាតាមផ្លូវច្បាប់រវាងទស្សនៈទាំងពីរនេះឡើយ។ សកម្មភាពតុលាការ អាច (១) អនុវត្ត ដោយអនុលោមទៅតាមច្បាប់ជាធរមាន ឬ (២) មិនត្រូវបានអនុវត្តដោយអនុលោមទៅតាមច្បាប់ជាធរមាន ដែលក្នុងករណីនេះគឺចៅក្រមដែលចេញសេចក្តីសម្រេច បានធ្វើឡើងតាមអំពើចិត្ត និងហួសដែនសមត្ថកិច្ច និងសេចក្តីសម្រេចដែលមានវិការៈនីតិវិធី ដែលមោឃៈ និងមិនមានអានុភាពគតិយុត្តិ[40]។ អង្គបុរេជំនុំជម្រះបានសម្រេចជាឯកច្ឆ័ន្ទថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតចេញដីកាដំណោះស្រាយលើសពីមួយ សហចៅក្រមស៊ើបអង្កេតបានរំលោភបំពានទៅលើក្របខណ្ឌគតិយុត្តិ អ.វ.ត.ក។ ជាលទ្ធផល ដីកាដំណោះស្រាយផ្ទុយគ្នា ខុសច្បាប់ និងមានវិការៈនីតិវិធី ដែលជាលទ្ធផលគឺមោឃៈ[41]។

១៩. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា៖

ខណៈ អ.ប.ជ បានសម្រេចនៅក្នុងសេចក្តីពិចារណារបស់ខ្លួនក្នុងសំណុំរឿង០០៤/២ ថា

[38] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៧-២៨។

[39] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៦, ២៨, ៥៩។

[40] សូមមើល ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ឯកសារ D381/26 ("ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីការបស់ ស.ច.ស.ជ") កថាខណ្ឌ ១២-២៦។

[41] សូមមើល ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីការបស់ ស.ច.ស.ជ កថាខណ្ឌ ១២-២៦។

ការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា មិនត្រូវបានអនុញ្ញាត នៅក្រោមក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ការណ៍នេះមិនធ្វើឲ្យមានការច្រានចោលដីកាដំណោះស្រាយទាំងពីរឡើយ។ ផ្ទុយមកវិញ ស.ព.អ សន្និដ្ឋានថា ពេលនេះ អ.ប.ជ ត្រូវតែពិចារណាទៅលើឋានៈផ្លូវច្បាប់នៃដីកាដំណោះស្រាយនីមួយៗ ដូចដែលខ្លួនបានអនុវត្តចំពោះសំណុំរឿង ០០៤/២ ដើម្បីកំណត់ថាតើ ដីកាដំណោះស្រាយណាមួយ (ឬទាំងពីរ) មានកំហុសខាងនីតិវិធី ឬសាធាតុ ដែលតម្រូវឲ្យបដិសេធ[42]។

២០. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងទៀតថា មេធាវីការពារក្តីបង្ហាញដោយមិនត្រឹមត្រូវអំពីផលប៉ះពាល់នៃកំហុសអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេត[43]។ តាមពិតទៅ សហព្រះរាជអាជ្ញាអន្តរជាតិទេ ដែលបង្ហាញដោយមិនត្រឹមត្រូវអំពីផ្នែកជាឯកច្ឆ័ន្ទនៃការពិចារណាលើសំណុំរឿង ០០៤/០២ នោះ ដោយសហព្រះរាជអាជ្ញាអន្តរជាតិព្យាយាមបង្ហាញការសម្រេចជាឯកច្ឆ័ន្ទដែលមានភាពមិនស្របច្បាប់ និងសាមញ្ញ ទៅជាការសម្រេចដែលស្មុគស្មាញទៅវិញ។ នៅក្នុងការពិចារណាជាឯកច្ឆ័ន្ទ មិនមានចំណុចណាមួយដែលបង្ហាញថា អង្គបុរេជំនុំជម្រះមានចេតនាច្រានចោលដីកាដំណោះស្រាយតែមួយ នៅក្នុងកាលៈទេសៈទាំងនេះឡើយ ប៉ុន្តែ នេះគឺជាអ្វីដែលសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំដោយបំភ្លៃការពិត[44]។

២១. ជាសារវ័ន្ត សហព្រះរាជអាជ្ញាអន្តរជាតិមិនបានទទួលស្គាល់ពីផលវិបាកជាក់ស្តែងនៃការសម្រេចជាឯកច្ឆ័ន្ទនៅក្នុងការពិចារណាលើសំណុំរឿង ០០៤/០២ របស់អង្គបុរេជំនុំជម្រះ[45]។ សហចៅក្រមស៊ើបអង្កេតមិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ឆន្ទានុសិទ្ធិឯករាជ្យរបស់ខ្លួនឡើយ សហចៅក្រមស៊ើបអង្កេតត្រូវបានតម្រូវឲ្យចេញដីកាដំណោះស្រាយតែមួយ[46]។ នេះមានន័យថា ដីកាដំណោះស្រាយទាំងពីរនេះគឺមោឃៈ។ ដូចដែលបានលើកឡើងនៅក្នុងចម្លើយតបរបស់មេធាវីការពារក្តីចំពោះបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ នេះគឺជាច្បាប់ធម្មតាដែលថា ដីកាសម្រេចរបស់តុលាការ

---

[42] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥៩ (ដាក់អក្សរទ្រេតក្នុងច្បាប់ដើម)។

[43] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៧-២៨។

[44] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ២៧-២៨។

[45] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៣០។

[46] សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ១២១។

ដែលមិនមានមូលដ្ឋានគតិយុត្តិ គឺមោឃៈ ដែលមានន័យម្យ៉ាងទៀតថា ចំពោះចេតនា និងគោលបំណងទាំងអស់ ដីកានេះលែងមានអត្ថិភាពទៀតហើយ[47]។

២២. តាមវិធាន ៧៦(៥) នៃវិធានផ្ទៃក្នុង កិច្ចដែលមានវិការៈនីតិវិធី ហើយត្រូវបានមោឃភាព ឬលុបចោល លែងមានអត្ថិភាពទៀតហើយ កិច្ចនេះត្រូវបានដកចេញពីសំណុំរឿង ហើយត្រូវបានហាមឃាត់មិនឱ្យទាញសន្និដ្ឋានណាមួយពីកិច្ចនេះ ដើម្បីប្រឆាំងទៅនឹងភាគីនានាឡើយ[48]។ នីតិវិធីមោឃភាពនេះ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុង មាត្រា ២៨០ និងមាត្រា ២៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងមាត្រា ១៧៤ និង២០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង[49]។ នៅក្នុងយុត្តាធិការច្បាប់ស៊ីវិលក្រៅពីច្បាប់កម្ពុជានិងបារាំង មានការចែងកំណត់ដោយច្បាប់ថា ដីកាសម្រេចដែលចេញដោយខុសច្បាប់ គឺមោឃៈ ហើយជាលទ្ធផល មិនមានអានុភាពគតិយុត្តិឡើយ[50]។ ចំណុចនេះត្រូវបានចាត់ទុកផងដែរថាជាច្បាប់សាមញ្ញ នៅក្នុងយុត្តិសាស្ត្រច្បាប់កុំមិនឡ "អានុភាពនៃការសម្រេចថាសាលក្រមមួយមោឃៈ ត្រូវបានកំណត់ច្បាស់។ គឺថា វាហាក់ដូចជា កិច្ចដំណើរការនីតិវិធីបែបនេះមិនបានកើតមានឡើង ហើយសាលក្រមគឺគ្រាន់តែជាមោឃភាព ហើយភាគីគឺស្ថិតក្នុងស្ថានភាពដដែល ដូចជាមិនមានសាលក្រម"[51]។

២៣. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានផ្តល់ភស្តុតាងគាំទ្រការអះអាងរបស់គាត់ដែលថា សំណើសុំ

---

[47] សូមមើល ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីការបស់ ស.ច.ស.ជ កថាខណ្ឌ ១២-២៦។

[48] អង្គបុរេជំនុំជម្រះបង្គាប់ឱ្យ "លុបចោល និងដកចេញ" ពីសំណុំរឿងនូវផ្នែកនៃកិច្ចស៊ើបសួរដែលមានវិការៈនីតិវិធីក្នុង សាលដីកាលើសំណើរបស់ យឹម ទិត្យ សុំធ្វើមោឃភាពឯកសារស៊ើបអង្កេតដែលធ្វើឡើងដោយ Paolo STOCCHI ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧ ឯកសារ D351/1/4 កថាខណ្ឌ ៣៦ ទំព័រ ១៧។

[49] ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៨០, ២៨១, ក្រមនីតិវិធីព្រហ្មទណ្ឌបារាំង មាត្រា ១៧៤, ២០៦។

[50] សូមមើលឧទាហរណ៍ សាធារណរដ្ឋកូរ៉េ ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ ៩៧៦៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ មាត្រា ៣២៧(២), ក្រមនីតិវិធីព្រហ្មទណ្ឌលីប៊ី និងច្បាប់បន្ថែម ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មាត្រា ៣០៤, ៣០៩។

[51] រឿងក្តី *Romito តទល់នឹង Maxwell*, 227 N.E.2d, 223, 224 (Ohio 1967)។ សូមមើលផងដែរ រឿងក្តី *រដ្ឋ តទល់នឹង Bezak*, 868 N.E.2d 961, 963 (Ohio 2007), រឿងក្តី *Ex parte Seidel*, 39 S.W.3d 221, 225 (Tex. Crim. App. 2001), រឿងក្តី *រដ្ឋ តទល់នឹង Simpkins*, 884 N.E.2d 568, 575 (Ohio 2008), រឿងក្តី *R (តាមបណ្តឹងរបស់ Miller) (ដើមបណ្តឹង) តទល់នឹងនាយករដ្ឋមន្ត្រី (ចុងចម្លើយ) Cherry និងអ្នកផ្សេងទៀត (ចុងចម្លើយ) តទល់នឹងជំនួយការទៅក្រមប្រទេសស្កុតលេន (ដើមបណ្តឹង) (ប្រទេសស្កុតលេន)* [2019] UKSC 41 កថាខណ្ឌ ៦៩, រឿងក្តី *R (តាមបណ្តឹងរបស់ UNISON) (ដើមបណ្តឹង) តទល់នឹង Lord Chancellor (ចុងចម្លើយ)* [2017] UKSC 51 កថាខណ្ឌ ១១៩។

នៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ ផ្ទុយទៅនឹងច្បាប់ឡើយ។ ការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិដែលថា មានតែដីកាដំណោះស្រាយរបស់សហព្រះរាជអាជ្ញាអន្តរជាតិតែមួយគត់ ដែលមានអានុភាពនោះ គឺផ្អែកទៅលើការបកស្រាយបែបក្តោបរួមទៅលើពាក្យ "កិច្ចស៊ើបសួរត្រូវបន្ត" ដែលចំណុចនេះមិនអាចឆ្លងផុតការត្រួតពិនិត្យដោយល្អិតល្អន់ណាមួយឡើយ[52]។ ការបកស្រាយតែមួយនៃ "កិច្ចស៊ើបសួរត្រូវបន្ត" ដែលស្របជាមួយក្របខណ្ឌគតិយុត្តិ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ព្រមទាំងនីតិវិធីព្រហ្មទណ្ឌរបស់កម្ពុជា គឺថា អង្គបុរេជំនុំជម្រះត្រូវចេញដីកាដំណោះស្រាយផ្ទាល់របស់ខ្លួន[53]។

២៤. នៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង មានចន្លោះប្រហោង ដោយសារតែអ្នកតាក់តែងសេចក្តីព្រាងមិនអាចប្រមើលមើលឃើញការចេញដីកាដំណោះស្រាយពីរដាច់ពីគ្នា[54]។ ការបកស្រាយបទប្បញ្ញត្តិវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ស្តីពីមោឃភាពនៃដីកាដំណោះស្រាយ ដែលមានវិការៈនីតិវិធីរួមទាំងចន្លោះប្រហោង នៅក្នុងនោះ ត្រូវអនុវត្តស្របតាមវិធានបកស្រាយនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល[55]។ បន្ទាប់ពីអនុវត្តវិធានបកស្រាយនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល ទៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក ហើយ អង្គបុរេជំនុំជម្រះត្រូវពិនិត្យមើលលើនីតិវិធីកម្ពុជា ហើយបន្ទាប់មក នីតិវិធីនៅកម្រិតអន្តរជាតិ[56]។ ការបកស្រាយដោយត្រឹមត្រូវចំពោះវិធាន ៦៧(២) គឺដោយពិចារណាទៅលើទីតាំងរបស់វានៅក្នុងប្រព័ន្ធច្បាប់ អ.វ.ត.ក រួមទាំងបរិបទនៃនីតិវិធីមោឃភាពនៅក្នុងវិធាន ៧៦ នៃវិធានផ្ទៃក្នុង និងគោលដៅ និងគោលការណ៍ជាមូលដ្ឋានសំខាន់សម្រាប់មោឃភាពមុនពេលជំនុំ

---

[52] ចម្លើយតបរបស់ ស.ព.អ. កថាខណ្ឌ ៣១-៣៦, ៤០, ៤១។

[53] វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង, វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ១២៩, ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ២៨១, សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ៣០, សំណុំរឿង ០០១ សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ កាំង ហ្គេចអ៊ាវ ហៅ ឌុច" ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៨ ឯកសារ D99/3/42 កថាខណ្ឌ ៤០, សំណុំរឿង ០០៤/០១ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ឯកសារ D308/3/1/20 កថាខណ្ឌ ២២។

[54] សូមមើល ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីការបស់ ស.ច.ស.ជ កថាខណ្ឌ ១៤។

[55] សូមមើល ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីការបស់ ស.ច.ស.ជ កថាខណ្ឌ ១៥។

[56] សូមមើល ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីការបស់ ស.ច.ស.ជ កថាខណ្ឌ ១៨។

ជម្រះ តម្រូវថាអានុភាពនៃការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤/០២ គឺថា ដីកាដំណោះស្រាយទាំងពីរគឺមោឃៈ។ ចំណុចនេះត្រូវបានគាំទ្របន្ថែមទៀតដោយនីតិវិធីព្រហ្មទណ្ឌបារាំង និងកម្ពុជា និងទស្សនៈ "មោឃភាព" ដែលមាននៅក្នុងយុត្តាធិការជាតិនិងអន្តរជាតិ[57]។ អង្គបុរេជំនុំជម្រះក៏បានសម្រេចផងដែរថា អង្គជំនុំជម្រះ "បានបំពេញតួនាទីជាសភាស៊ើបសួរ [...] នៅក្នុង អ.វ.ត.ក" ហើយនៅពេលបានទទួលបណ្តឹងឧទ្ធរណ៍ ប្រឆាំងនឹងដីកាដំណោះស្រាយ "វិធាន ៧៩(១) នៃវិធានផ្ទៃក្នុង ស្នើឡើងថា អង្គបុរេជំនុំជម្រះមានអំណាចចេញដីកាដំណោះស្រាយថ្មីមួយ ឬចេញដីកាដំណោះស្រាយដែលបានកែប្រែរួច។ ដីកានេះនឹងយកមកធ្វើជាមូលដ្ឋាននៃការជំនុំជម្រះ"[58]។ ចំណុចនេះគឺស្របជាមួយនិយមន័យនៃដីកាដំណោះស្រាយដែលមាននៅក្នុង សទ្ទានុក្រមនៃវិធានផ្ទៃក្នុងដែលថាជា "ដីកាចុងក្រោយដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ឬអង្គបុរេជំនុំជម្រះ នៅពេលបញ្ចប់ដំណើរការស៊ើបសួរ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងចោទប្រកាន់"[59]។ ការបកស្រាយតាមផ្លូវច្បាប់ដែលសមស្របទៅលើបទប្បញ្ញត្តិទាំងអស់នេះនៃក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក បានបង្ហាញយ៉ាងច្បាស់ថា ឧបាស្រ័យតែមួយគត់ ដែលអង្គបុរេជំនុំជម្រះអាចប្រើប្រាស់បាន គឺអ្វីដែលមេធាវីការពារក្តីបានស្នើឡើង ហើយដែលសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញឲ្យឃើញថាផ្ទុយពីក្របខណ្ឌនេះឡើយ។

២៥. សហព្រះរាជអាជ្ញាអន្តរជាតិបានទទួលស្គាល់ថា ឧបាស្រ័យដែលបានស្នើឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តី ប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ ស្ថិតក្រោមច្បាប់ ដោយសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងយ៉ាងត្រឹមត្រូវនៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហព្រះរាជអាជ្ញាជាតិ ដែលថា "យុត្តិសាស្ត្រ អ.វ.ត.ក និងច្បាប់អន្តរជាតិបានចែងយ៉ាងច្បាស់ថា នៅពេលមានភស្តុតាងបង្ហាញថា សេចក្តីសម្រេចតាមឆន្ទានុសិទ្ធិមួយ ពឹងផ្អែកលើសំអាងហេតុ និងសំអាងច្បាប់ខុស អង្គជំនុំជម្រះសាលាឧទ្ធរណ៍ត្រូវធ្វើមោឃភាពសេចក្តីសម្រេចនោះ ដោយត្រូវបញ្ជូនត្រឡប់ទៅតុលាការកម្រិតទាបវិញ

---

[57] សូមមើល ចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីការបស់ ស.ច.ស.ជ កថាខណ្ឌ ១១-២៦។

[58] សូមមើល បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៣៩, សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/០២ កថាខណ្ឌ ៣២។

[59] វិធានផ្ទៃក្នុង សទ្ទានុក្រម ទំព័រ ៨៣។

ដើម្បីឱ្យអនុវត្តបទដ្ឋានត្រឹមត្រូវ ឬចេញសេចក្តីសម្រេចផ្ទាល់លើបញ្ហានេះ"[60]។ ប៉ុន្តែ សហព្រះរាជអាជ្ញាអន្តរជាតិបានលុបចោលត្រង់ចំណុចនេះ នៅក្នុងការថ្លែងបញ្ជាក់ពីបទដ្ឋានត្រួតពិនិត្យឡើងវិញ របស់អង្គបុរេជំនុំជម្រះនៅក្នុងចម្លើយតបរបស់គាត់[61]។ សហព្រះរាជអាជ្ញាអន្តរជាតិបានកំណត់ខុសចំពោះយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ ដោយអះអាងថា នៅពេលដែលមានការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត មានតែដីកាសម្រេចចោទប្រកាន់បញ្ជូនទៅជំនុំជម្រះប៉ុណ្ណោះ ដែលស្របគ្នាជាមួយគោលជំហរស្វ័យប្រវត្តិ ដែលថា "ការស៊ើបអង្កេតត្រូវធ្វើបន្តទៀត"[62]។ នៅក្នុងការធ្វើដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិអាចមើលរំលង ឬបង្ហាញដោយខុសពីសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/០២។

២៦. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថា មេធាវីការពារក្តីបានបកស្រាយ ឬអនុវត្តខុសនូវគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ នៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ[63]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងដោយខុសថា គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ មិនអនុវត្តចំពោះការសម្រេចលើអង្គហេតុនៅដំណាក់កាលមុនពេលជំនុំជម្រះទេ ដែលនេះជាការបង្ហាញដោយខុសពីច្បាប់ជាធរមាន និងការជាបង្ហាញដោយខុសពីយុត្តិសាស្ត្រដែលបានដកស្រង់នៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ[64]។

២៧. នៅក្នុងសាលក្រមក្នុងសំណុំរឿង ០០២/០១ និងសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងមិនបានសម្រេចបញ្ជាក់ ឬកំណត់ថា គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ កម្រិតយ៉ាងច្បាស់ត្រឹមតែដំណាក់កាលជំនុំជម្រះទេ[65]។ ការដែលអង្គជំនុំជម្រះសាលាដំបូង

---

[60] បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ ស.ច.ស.ជ កថាខណ្ឌ៨(ដាក់អក្សរទ្រេតក្នុងច្បាប់ដើម)។

[61] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ១៤។

[62] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៣១, ៣២។

[63] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៤៤, ៤៥។

[64] បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៣១-៣៦។ ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៤៤, ៤៥។

[65] សូមមើល សំណុំរឿង ០០២/០១ សាលក្រមសំណុំរឿង ០០២/០១ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ឯកសារ E313 កថាខណ្ឌ ២២, សំណុំរឿង ០០២/០២ សាលក្រមសំណុំរឿង ០០២/០២ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ ឯកសារ E465 កថាខណ្ឌ ២១, ៣០១៤។

បដិសេធចំពោះអង្គបុរេជំនុំជម្រះលើបញ្ហានៃច្បាប់សារធាតុ មិនមានភាពពាក់ព័ន្ធឡើយ។ នៅក្នុងសំអាងហេតុរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងមិនបានច្រានចោលការអំពាវនាវរបស់អង្គបុរេជំនុំជម្រះចំពោះគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ នៅដំណាក់កាលមុនពេលជំនុំជម្រះ ហើយក៏មិនបានច្រានចោលកត្តាវិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ នៅក្នុងសំអាងហេតុរបស់អង្គជំនុំជម្រះដែរ[66]។ ការសម្រេចរបស់អង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុងរឿងក្តី *Bemba* បង្ហាញថា គោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ អនុវត្តនៅដំណាក់កាលមុនជំនុំជម្រះ បើទោះបីជាបទដ្ឋានបង្ហាញភស្តុតាង មានកម្រិតទាបជាងបទដ្ឋានលើសពីវិមតិសង្ស័យក្តី[67]។ ឧបាស្រ័យដែលបានស្នើសុំនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ តម្រូវឲ្យមានគោរពតាមយ៉ាងខ្ជាប់ខ្ជួនចំពោះគោលការណ៍វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់

---

[66] នៅក្នុងសំណុំរឿង ០០២ អ.ប.ជ យល់ឃើញថា ដោយមិនមានទម្លាប់អនុវត្តរបស់រដ្ឋច្បាស់លាស់ និង*ទស្សនៈច្បាប់* ខ្លួនមិនអាចកំណត់បានពី "ដំណាក់កាលដែលមានបញ្ហាចន្លោះពីឆ្នាំ១៩៦៨ រហូតដល់ឆ្នាំ១៩៨៤" នៅពេលដែលទំនាក់ទំនងនឹងជម្លោះប្រដាប់អាវុធលែងជាលក្ខខណ្ឌតម្រូវសម្រាប់ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការអនុវត្តគោលការណ៍ *វិមតិសង្ស័យនឹងបានជាប្រយោជន៍ដល់ជនជាប់ចោទ* អ.ប.ជ. បានដោះស្រាយភាពមិនច្បាស់លាស់នេះ ដោយផ្តល់ប្រយោជន៍ដល់ជនជាប់ចោទ។ អង្គជំនុំជម្រះសាលាដំបូងច្រានចោលការអះអាងរបស់ អ.ប.ជ. ដោយផ្អែកលើការវិភាគឯករាជ្យរបស់ខ្លួនអំពីទម្លាប់អនុវត្តរបស់រដ្ឋ និង*ទស្សនៈច្បាប់* ដោយអះអាងថា ទំនាក់ទំនងនឹងជម្លោះប្រដាប់អាវុធមិនមែនជាផ្នែកមួយនៃនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ ចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ទេ។ សូមមើល សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/1/30 កថាខណ្ឌ ៣១០, សំណុំរឿង ០០២ សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី១៥ ខែមេសា ឆ្នាំ២០១១ ឯកសារ D427/2/15 កថាខណ្ឌ ១៤៤, សំណុំរឿង ០០២ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១១ ឯកសារ E95/8 កថាខណ្ឌ ៣៣។

[67] អង្គបុរេជំនុំជម្រះនៃតុលាការ ICC នៅក្នុងរឿងក្តី *Bemba* បានកត់សម្គាល់ជាក់លាក់ថា លក្ខន្តិកៈទីក្រុងរ៉ូមបង្កើតជាបទដ្ឋានខ្ពស់ចំនួន ៣ ផ្សេងគ្នាសម្រាប់ដំណាក់កាលនីតិវិធីនីមួយៗ និងថា បទដ្ឋានដែលអនុវត្តនៅដំណាក់កាលបញ្ជាក់ពីការចោទប្រកាន់ទាបជាងបទដ្ឋានហួសពីវិមតិសង្ស័យ។ ទោះជាយ៉ាងនេះក្តី អង្គបុរេជំនុំជម្រះជឿជាក់ថា ក្នុងការធ្វើសេចក្តីសម្រេចលើការបញ្ជាក់ពីការចោទប្រកាន់ "អង្គជំនុំជម្រះគោរពតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលជាផ្នែកមួយនៃសច្ចធារណ៍និរទោស ពោលគឺ វាជាគោលការណ៍ទូទៅមួយនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវអនុវត្តដូចគ្នានៅគ្រប់ដំណាក់កាលនីតិវិធី រួមទាំងដំណាក់កាលមុនអង្គសេចក្តី", អង្គបុរេជំនុំជម្រះ II នៃតុលាការ ICC រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Bemba* (ICC-01/05-01/08-424) "សេចក្តីសម្រេចយោងតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមអំពីការចោទប្រកាន់របស់រដ្ឋអាជ្ញាប្រឆាំងនឹង Jean-Pierre Bemba Gombo" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ២៧-៣១។

ចោទ និងការអនុវត្តគោលការណ៍នេះ នៅដំណាក់កាលនេះនៃកិច្ចដំណើរការនីតិវិធី។

២៨. សហព្រះរាជអាជ្ញាអន្តរជាតិបានជាន់ឈ្លីលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ ដែលជាសិទ្ធិជាមូលដ្ឋានបំផុត ដែលត្រូវបានការពារដោយវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយបានលើកឡើងដោយខុសឆ្គងថា "ផ្លូវឆ្ពោះទៅមុខគឺច្បាស់ក្រឡែត និងមិនត្រូវបានបដិសេធចោលដោយ [...] គោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ឡើយ [...]"[68]។ សហព្រះរាជអាជ្ញាអន្តរជាតិបានបកស្រាយដោយមិនត្រឹមត្រូវពីវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយលើកឡើងមិនត្រឹមត្រូវថា "ការពិតបើសិនជាមានសេណារីយ៉ូណាមួយ ដែលច្បាប់មិនអាចបញ្ជាក់បានច្បាស់លាស់ វាមិនមែនបង្កើតឱ្យមាន "ការសង្ស័យ" ដែលធ្វើឱ្យចុងចោទតែងតែទទួលបានផលប្រយោជន៍ពីវានោះទេ" ដែលហាក់ដូចជាថា សហព្រះរាជអាជ្ញាអន្តរជាតិចាត់ទុកការគណនាចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនជាប់ចោទ គឺជាល្បែងភ្នាល់យកចាញ់ឈ្នះ[69]។ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានរម្លឹកថា អង្គបុរេជំនុំជម្រះបានសម្រេចថា សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានការពារផងដែរដោយ វិធាន ២១ នៃវិធានផ្ទៃក្នុង មិនអាច "ជះឥទ្ធិពលផ្ទាល់ និងផ្ទុយចំពោះជំហររបស់ជនជាប់ចោទ ដូចជាថា ត្រូវយកទៅជំនុំជម្រះទោសទៅ ឬក៏អត់នោះ [...]"[70]។ សិទ្ធិដែលការពារដោយវិធាន ២១ នៃវិធានផ្ទៃក្នុង គឺច្បាស់លាស់ណាស់ ហើយមិនអាចបកស្រាយខុសពីនេះនៅក្នុងស្ថានភាពផ្សេងនោះឡើយ។

---

[68] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥១។

[69] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥៤៖ "ទោះក្នុងព្រឹត្តិការណ៍ណាក៏ដោយ ការអនុវត្តតាមន័យចង្អៀតរបស់វាចំពោះទ្វេគ្រោះនៃច្បាប់ គឺត្រូវបានកម្រិតត្រឹមតែមន្ទិលដែលនៅសេសសល់ក្រោយពី *ការបកស្រាយ* ដោយប្រើវិធានច្បាប់ស៊ីវិលសម្រាប់ការបកស្រាយ មានន័យថា ក្រោយពីមានការពិចារណាទៅលើពាក្យពេចន៍នៃបទប្បញ្ញត្តិនោះ ព្រមទាំងប្រព័ន្ធ (រួមទាំង ទំនាក់ទំនងរបស់វាទៅនឹងគោលការណ៍ជាមូលដ្ឋានដ៏ចម្បងរបស់វា) និងគោលបំណងរបស់វា។ គ្រប់អត្ថបទច្បាប់សុទ្ធតែជាកម្មវត្ថុនៃការបកស្រាយ ហើយការពិត បើសិនជាមានសេណារីយ៉ូណាមួយដែលច្បាប់មិនអាចបញ្ជាក់បានច្បាស់លាស់ មិនមែនថាបង្កើតឱ្យមាន "ការសង្ស័យ" ដែលធ្វើឱ្យចុងចោទតែងតែទទួលបានផលប្រយោជន៍ពីវានោះទេ។ ដូច អ.ជ.ត.ក. បានសម្រេចដែរថា "*គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ក្នុងការដោះស្រាយទៅលើ*ភាពខ្វះចន្លោះ*នៃច្បាប់ឡើយ" (ដាក់អក្សរទ្រេតក្នុងច្បាប់ដើម)។

[70] សំណុំរឿង ០០២ សាលដីកាលើបណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់សហចៅក្រមស៊ើបអង្កេតលើភាពអាចទទួលយកបាននៃពាក្យតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ ឯកសារ D411/3/6 កថាខណ្ឌ ៩៧។

២៩. សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងដោយខុសទៀតថា គោលការណ៍ *វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* គឺ "មិនអាចអនុវត្តបានផងដែរ ចំពោះបញ្ហានីតិវិធីនានា ដូចជាបញ្ហាមួយនេះ" ដោយសារតែ "វាគឺជាវិធាននៃភស្តុតាង ហើយវាមិនមែនជាវិធាន សម្រាប់ការបកស្រាយច្បាប់ទេ"[71]។ សហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញដោយមិនត្រឹមត្រូវពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល ដោយដកស្រង់មិនត្រឹមត្រូវ "ដូចដែល អ.ជ.ត.ក បានសម្រេចដែរថា "គោលការណ៍ *វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ក្នុងការដោះស្រាយទៅលើភាពខ្វះចន្លោះនៃច្បាប់ឡើយ"[72]។ តាមពិតទៅការសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល គឺថា "គោលការណ៍ *វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* នឹងមិនមានភាពចាំបាច់ ក្នុងការដោះស្រាយទៅលើភាពខ្វះចន្លោះនៃច្បាប់ឡើយ"[73]។ បើទោះបីជាមានភាពខ្វះចន្លោះ នៅក្នុងវិធាន ៦៧(១) នៃវិធានផ្ទៃក្នុងក្តី មិនមានមន្ទិលឡើយថា ដីកាដំណោះស្រាយដែលចេញដោយខុសច្បាប់ក្នុងសំណុំរឿង ០០៤ គឺមោឃៈ។

៣០. លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងដោយមិនត្រឹមត្រូវថា មេធាវីការពារក្តីបានស្នើសុំ "អត្ថប្រយោជន៍ស្វ័យប្រវត្តិ" ដោយសារតែការបកស្រាយទៅលើវិធានផ្ទៃក្នុង[74]។ សហព្រះរាជអាជ្ញាអន្តរជាតិបង្ហាញដោយខុស និងបំភ្លើសលើគោលជំហររបស់មេធាវីការពារក្តីដោយលើកឡើងថា "បើសិនជាភាពមិនប្រាកដប្រជាខាងនីតិវិធីទាំងអស់ នឹងត្រូវបានអនុញ្ញាតជាផលប្រយោជន៍ដល់ជនត្រូវចោទដោយស្វ័យប្រវត្តិ រហូតដល់ចំណុចដែលអាចរំលត់កិច្ចដំណើរការនីតិវិធីបានមែន នោះវាជាការរំលោភច្បាប់នីតិវិធីកម្ពុជា (និងច្បាប់នីតិវិធីបារាំង)"[75]។ មេធាវីការពារក្តីមិនបានអះអាងពីសិទ្ធិបែបនេះទេ។ ជាថ្មីម្តងទៀត សហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញពីចេតនាក្នុងការបង្ហាញដោយមិនត្រឹមត្រូវពីអង្គហេតុ យុត្តិសាស្ត្រ និងសារណារបស់ភាគីក្នុងករណីនេះ គឺញត្តិរបស់មេធាវីការពារក្តីដែលគ្រាន់តែស្នើសុំឱ្យអង្គបុរេជំនុំជម្រះគោរពយ៉ាងម៉ឺងម៉ាត់ទៅតាមក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ប៉ុណ្ណោះ។

---

[71] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥២។

[72] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥៤។

[73] សំណុំរឿង ០០២/០១ សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់ ខៀវ សំផន ស្តីពីសំណើដោះលែងជាបន្ទាន់ ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ ឯកសារ E50/3/1/4 កថាខណ្ឌ ៣១ (ដាក់អក្សរទ្រេតបញ្ជាក់បន្ថែម)។

[74] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥៥។

[75] ចម្លើយតបរបស់ ស.ព.អ កថាខណ្ឌ ៥៧។

## សេចក្តីសន្និដ្ឋាន

៣១. ស្ថានភាពបច្ចុប្បន្ននៅក្នុងសំណុំរឿងរបស់លោក យឹម ទិត្យ គឺថា បណ្តឹងឧទ្ធរណ៍របស់ភាគី ត្រូវបានអង្គជំនុំជម្រះធ្វើសវនាការ ហើយបានសម្រេចជាឯកច្ឆ័ន្ទថា ដីកាដែលរងការជំទាស់មិនមានមូលដ្ឋាននីតិវិធីតាមច្បាប់ឡើយ។ មិនមានឯកសារដែលចេញដោយសុពលភាព ដែលអាចឱ្យការជំនុំជម្រះលោក យឹម ទិត្យ បន្តទៅមុខបានឡើយ។ លោក យឹម ទិត្យ មិនអាចត្រូវបានជំនុំជម្រះដោយផ្អែកលើដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលមោឃៈនោះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិវិភាគមិនត្រឹមត្រូវទៅលើការសម្រេចជាឯកច្ឆ័ន្ទរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង០០៤/០២ និងផលវិបាកនៃការសម្រេចនេះចំពោះសំណុំរឿង០០៤។ នៅក្នុងការវិភាគនោះ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបង្ហាញថា បណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ បង្ហាញដោយមិនត្រឹមត្រូវលើផលវិបាកនៃដីកាដំណោះស្រាយដែលខុសច្បាប់ និងថា សំណើដែលមេធាវីការពារក្តីបានស្នើសុំ ផ្ទុយទៅនឹងច្បាប់នោះឡើយ។

៣២. ហេតុដូច្នេះ លទ្ធផលនៃបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះស្រាយពីរ គឺបានធ្វើរួចទៅហើយ និងមិនអាចជៀសផុតឡើយ។ មធ្យោបាយគតិយុត្តិតែមួយគត់ដែលមានសម្រាប់អង្គបុរេជំនុំជម្រះ គឺ សំណើសុំផ្សេងៗរបស់មេធាវីការពារក្តី។ ដោយសារតែសុពលភាពនៃនីតិវិធីនៅក្នុងការស៊ើបអង្កេតតាមផ្លូវតុលាការ មិនអាចលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬអង្គជំនុំជម្រះតុលាការកំពូល[76] ដូច្នេះ អង្គបុរេជំនុំជម្រះចាំបាច់ត្រូវតែផ្តល់ការសន្និដ្ឋានបញ្ចប់ជាក់លាក់ចំពោះកិច្ចដំណើរការនីតិវិធីទាំងអស់នេះ។

## ឧបាស្រ័យ

**អាស្រ័យហេតុនេះ** ផ្អែកលើហេតុផលទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីស្នើដោយសេចក្តីគោរពថា ក្នុងការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន និងដើម្បីជាផលប្រយោជន៍យុត្តិធម៌ សូមអង្គបុរេជំនុំជម្រះ៖

(១) **បដិសេធ** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង

(២) **ទទួលយក** តាមបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីប្រឆាំងនឹងការចេញដីកាដំណោះ

---

[76] វិធាន ៧៦(៧) នៃវិធានផ្ទៃក្នុង។

ស្រាយចំនួនពីរ និង

(៣) **បដិសេធ** ដីកាដំណោះស្រាយដែលមានវិការៈទាំងស្រុងជាស្ថាពរ និងលើកលែងការចោទប្រកាន់ប្រឆាំងលោក យឹម ទិត្យ ឬ

(៤) **បដិសេធ** ដីកាដំណោះស្រាយដែលមានវិការៈ ហើយបង្វិលសំណុំរឿងទៅសហចៅក្រមស៊ើបអង្កេតវិញ ដោយមានដីកាបង្គាប់ឲ្យចេញដីកាដំណោះស្រាយរួមតែមួយ អនុលោមតាមច្បាប់ជាធរមាន ដោយកត់សម្គាល់ថា ការខ្វែងយោបល់គ្នាដែលនៅមានទាំងឡាយ ចាំបាច់ត្រូវតែដោះស្រាយដោយផ្តល់ជាប្រយោជន៍ដល់លោក យឹម ទិត្យ ឬ

(៥) **បដិសេធ** ដីកាដំណោះស្រាយដែលមានវិការៈ ហើយធ្វើការវាយតម្លៃទៅលើសំណុំរឿង ០០៤ ដោយខ្លួនឯង ហើយចេញដីកាដំណោះស្រាយរបស់អង្គបុរេជំនុំជម្រះផ្ទាល់ ដោយចោទប្រកាន់លោក យឹម ទិត្យ បញ្ជូនទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់ប្រឆាំងលោក យឹម ទិត្យ។

សូម លោក លោកស្រី ចៅក្រមទទួលការគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

______________________ ______________________

សូ មូស្សេទី Suzana TOMANOVIĆ

សហមេធាវីការពារក្តីលោក យឹម ទិត្យ

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០